**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍ**
**តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**
**ខេត្តក្រចេះ**
**ស្រុកព្រែកប្រសព្វ**

## របាយការណ៍ស្តីពីការរៀបចំទិន្នន័យដើមគ្រា នៃការអភិវឌ្ឍសមត្ថភាព រដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ស្រុកព្រែកប្រសព្វ

**១.ប្រវត្តិ:**

ផែនការអនុវត្តរយៈពេលបីឆ្នាំ(ផអ៣) គឺជាផែនការគាំទ្រការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល ។ ផែនការនេះផ្តោតសំខាន់ទៅលើការរៀបចំឡើងនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង រួមជាមួយនឹងការបង្កើត និងការអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ អោយក្លាយទៅជាស្ថាប័នសម្រាប់អភិបាលកិច្ចមូលដ្ឋាន និងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តសិទ្ធក្នុងការអនុវត្តអាណត្តិរបស់ខ្លួន ដោយរួមបញ្ចូលទាំងការផ្តល់សេវាសាធារណៈស្របតាមគោលការណ៍នានានៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ។ នាពេលបច្ចុប្បន្ននេះ រចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងសំខាន់ៗនៃរដ្ឋបាលថ្នាក់នេះ ត្រូវបានរៀបចំឡើងវិញ និងកំពុងត្រូវបានដាក់អោយដំណើរការជាបណ្តើរៗ ក្នុងស្ថានភាពមួយដែលមានតម្រូវការយ៉ាងខ្លាំងផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងសមត្ថភាព ។ អាស្រ័យហេតុនេះកិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាព គឺជាកត្តាសត្យានុម័តក្នុងការកំណត់ពីភាពជោគជ័យ នៃការងារកំណែទម្រង់នៃរដ្ឋបាលថ្នាក់ ក្រុង ស្រុក ខណ្ឌ នេះ ។

ផ្អែកតាម ផអ៣ នៅចុងឆ្នាំ ២០១៣ បុគ្គលិក និងអ្នកដឹកនាំទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងមានសមត្ថភាពប្រើប្រាស់អោយអស់លទ្ធភាពនូវសក្តានុពលរបស់ខ្លួនដើម្បីអនុវត្តតួនាទី និងការទទួលខុសត្រូវដែលបានផ្ទេរអោយប្រកបដោយប្រសិទ្ធភាព ។

ក្នុងស្ថានភាពចំពោះមុខនេះ ដែលសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅមានកំរិតនៅឡើយ សម្រាប់ការអនុវត្តតួនាទី ភារកិច្ច ដូចដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់អនុវត្តច្បាប់នេះ ។ ហេតុនេះកិច្ចអន្តរាគមន៍អភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌអនុវត្ត ផអ៣ នឹងត្រូវរៀបចំឡើងយ៉ាងច្រើនជាបន្តបន្ទាប់ ។

ដើម្បីបំពេញតម្រូវការនៅថ្នាក់មូលដ្ឋានក្នុងការលើកកម្ពស់អភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលស្រុក ស្រុកព្រែកប្រសព្វ បានរៀបចំទិន្នន័យដើមគ្រានៃការអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលស្រុកស្របតាមគោលការណ៍ណែនាំ ។

ស្រុកព្រែកប្រសព្វ ជាស្រុកមួយរបស់ខេត្តក្រចេះ មានព្រំប្រទល់ខាងកើតទល់នឹងទន្លេមេគង្គ ខាងលិចទល់នឹងស្រុកសន្ទុក ខេត្តកំពង់ធំ ខាងជើងទល់នឹងឃុំវឌ្ឍនៈ ស្រុកសំបូរ និងខាងត្បូងទល់នឹងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ស្រុកព្រែកប្រសព្វមាន ៨ឃុំ និងមាន ៤៨ភូមិ មានផ្ទៃដីសរុប ១,៣៧៣.២២ គីឡូម៉ែត្រការ៉េ មានប្រជាជនសរុប ១៤,០១១គ្រួសារ មនុស្សសរុប ៦៧,៤៦៩នាក់ ស្រី ៣៤,៤៧៥ នាក់ មានដង់ ស៊ីតេប្រជាជន ៤៩ នាក់/គីឡូម៉ែត្រការ៉េ ។ ប្រជាពលរដ្ឋប្រមាណ៨៧.២៤% ជាកសិកររស់នៅ ពឹងផ្អែកលើ វិស័យកសិកម្ម ដែលជាវិស័យចម្បងក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងស្រុក។ ដោយមានការរៀបចំរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្រុកព្រែកប្រសព្វមានក្រុមប្រឹក្សាចំនួន១៥នាក់ ស្រី០៣នាក់ គណៈអភិបាលចំនួន៥នាក់ ស្រី០១នាក់ នាយករដ្ឋបាល០១នាក់ នាយករងរដ្ឋបាល០១នាក់ និងមានការិយាល័យចំណុះ៣ គឺ

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុមានមន្ត្រីចំនួន០៦នាក់ ស្រី០៤នាក់
- ការិយាល័យផែនការ និងគាំទ្រឃុំ មានមន្ត្រីចំនួន០៦នាក់ ស្ត្រី០៣នាក់
- ការិយាល័យអន្តរវិស័យមានមន្ត្រីចំនួន០៥នាក់ ស្ត្រី០២នាក់។

## ២.គោលបំណង:

គោលបំណងនៃការចុះប្រមូលទិន្នន័យដើមគ្រាអំពីសមត្ថភាពរបស់រដ្ឋបាលស្រុកព្រែកប្រសព្វ គឺដើម្បីធានាអោយមានទិន្នន័យមូលដ្ឋានពាក់ព័ន្ធសមត្ថភាពរបស់រដ្ឋបាលស្រុក ដែលជាមូលដ្ឋានសំរាប់ការកំណត់តម្រូវការ និងការវាស់វែងពីភាពរីកចំរើននៃសមត្ថភាពរបស់រដ្ឋបាលក្នុងអំឡុងពេលអនុវត្ត និងនៅពេលបញ្ចប់ផអពានៃកម្មវិធីជាតិ ។

## ៣-វិធីសាស្ត្រ:

| វិធីសាស្ត្រ៖ | ឧបករណ៍៖ |
|---|---|
| - ពិនិត្យឯកសារដែលមាន(បញ្ជីសំណួរ)<br>- ការសង្កេតផ្ទាល់(ចុះមូលដ្ឋានគោលដៅនៅសាលាស្រុកព្រែកប្រសព្វ)<br>- សម្ភាសន៍ (បុគ្គល ក្រុម និងអ្នកផ្តល់ព័តិមានសំខាន់ៗ)<br>- ការពិភាក្សាជាក្រុម ។ | - បញ្ជីសំណួររៀបចំដោយថ្នាក់ជាតិ<br>- បញ្ជីសំណួរសម្រាប់សម្ភាសន៍បុគ្គល<br>- បញ្ជីសំណួរសម្រាប់ការពិភាក្សាក្រុម<br>- ទម្រង់និងគំរូសម្រាប់សរសេររបាយការណ៍ ។ |

## ៤-លទ្ធផលនៃការអង្កេតទូទៅ

### ការអង្កេតទូទៅ

ក្រុមប្រឹក្សាស្រុកព្រែកប្រសព្វ បានបង្ករលក្ខណៈឱ្យក្រុមការងារ ចុះប្រមូលទិន្នន័យដើមគ្រា ទាក់ទងនឹងសមត្ថភាពរបស់មន្ត្រីរដ្ឋបាលស្រុក។ ជាមួយនេះ ការកត់សម្គាល់មួយទៀត បានបង្ហាញពីការយកចិត្ត

ទុកដាក់របស់រដ្ឋបាលស្រុក និងមានការលះបង់ខ្ពស់ក្នុងការចំណាយពេលវេលា ដើម្បីចូលរួមផ្តល់ព័ត៌មានដល់ក្រុមការងារ ក្នុងន័យរួមចំណែកអនុវត្តផែនការអនុវត្តរយៈពេល៣ឆ្នាំដំបូង នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**ចំណុចខ្លាំង**

- ក្រុមប្រឹក្សាទាំងអស់មានការចូលរួម
- គណៈអភិបាលទាំងអស់មានការចូលរួម
- ក្រុមគោលដៅយល់ពីគោលបំណងសម្រាប់ដំណើរសម្ភាសន៍ និងចូលរួមបានល្អ
- ការណាត់ជួបក្រុមគោលដៅទាន់ពេល និងមានអ្នកចូលរួមគ្រប់
- ទីតាំងនៃការធ្វើសម្ភាសន៍សមស្រប
- ពន្យល់ពីវិធីសាស្ត្រ ដើម្បីធ្វើឱ្យងាយក្រុមគោលដៅបានឆ្លើយតប។

**ចំណុចខ្សោយ**

- ក្រុមប្រឹក្សាពុំទាន់យល់ពីការអនុវត្តការងាររបស់គ.ក.ស.ក
- ការអនុវត្តពីតួនាទី និងភារកិច្ចរបស់មន្ត្រីរដ្ឋបាលសាលាស្រុកពុំទាន់បាលល្អ ។

**៥-អនុសាសន៍**

ដើម្បីរួមចំណែកដល់ការលើកកម្ពស់ប្រសិទ្ធភាពការងារ និងការធ្វើអោយប្រសើរ នូវការអនុវត្ត តួនាទី និងភារកិច្ចរបស់រដ្ឋបាលស្រុកព្រៃកប្រសព្វ ក្រុមប្រឹក្សាស្រុកគួរយក ចិត្តទុកដាក់ទៅលើចំណុចមួយចំនួនដូចខាងក្រោម៖

1. គួរពង្រឹងយន្តការគាំទ្រពីថ្នាក់ខេត្តដល់រដ្ឋបាលស្រុក
2. គួរពង្រឹងយន្តការគាំទ្រដល់រដ្ឋបាលឃុំ
3. ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ស្រុក គួរធ្វើការពិគ្រោះយោបល់ជាមួយប្រធានក្រុមប្រឹក្សាអំពីការពាក់ព័ន្ធមួយចំនួន ដូចជាការអនុវត្តការងាររបស់ គ.ក.ស.ក លើការរៀបចំផែនការសកម្មភាពប្រចាំត្រីមាស និងប្រចាំខែ ព្រមទាំងការរៀបចំផែនការថវិកាប្រចាំឆ្នាំរបស់គ.ក.ស.ក ការជួយគាំទ្រគ.ក.ស.ក
4. គណៈអភិបាលស្រុកព្រៃកប្រសព្វ គួរពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់នាយករដ្ឋបាល និងការិយាល័យទាំងបីរបស់ស្រុក ។

ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០១២

អ្នកសរសេរបាយការណ៍

ព្រីង សាមឿន